# របាយការណ៍ប្រចាំខែ កុម្ភៈ ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម

## I. សេចក្តីផ្តើម

### 1. ស្ថានភាពភូមិសាស្ត្រ ខេត្តកំពង់ចាម

ខេត្តកំពង់ចាម ស្ថិតនៅដែនដីភាគខាងកើតប្រទេសកម្ពុជា ដែលមានចម្ងាយ ១២៤គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ខេត្តក៏មានផ្លូវជាតិសំខាន់ៗឆ្លងកាត់ដូចជា ផ្លូវជាតិលេខ 6A ផ្លូវជាតិលេខ 7 ដែលមានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ធំ និងខេត្តក្រចេះ ខាងត្បូងជាប់ខេត្តព្រៃវែង ខេត្តកណ្តាល ខាងកើតជាប់ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ខាងលិចជាប់ខេត្តកំពង់ឆ្នាំង ។

បច្ចុប្បន្នខេត្តកំពង់ចាមចែកចេញជា ស្រុក-ក្រុង ឃុំ-សង្កាត់ និងភូមិរដ្ឋបាល ដែលមានក្រុងចំនួន ០១ក្រុង មានសង្កាត់ ០៤សង្កាត់ និងស្រុកចំនួន ០៩ស្រុក មានឃុំចំនួន ១០៥ឃុំ ស្មើនឹង ៩១៦ភូមិ ។

ខេត្តកំពង់ចាមមានផ្ទៃដីសរុប ៤៥៤៨,០៩គ.ម² ហើយមានអំណោយផលធម្មជាតិយ៉ាងល្អប្រសើរដល់ដំណាំកសិកម្ម ដំណាំស្បៀង កសិឧស្សាហកម្មផងដែរ ។ ខេត្តកំពង់ចាម មានប្រជាពលរដ្ឋសរុប ១.០៩៧.០៨៥នាក់ ចំនួនស្ត្រីសរុប ៥៦២.០៨៥នាក់ ចំនួនគ្រួសារសរុប ២៥១.៤៥៨គ្រួសារ ដង់ស៊ីតេ ២៤១នាក់/គ.ម² ប្រជាកសិករប្រកបមុខរបរកសិកម្មចំនួន ៨០% មុខរបរសិប្បកម្ម ០.៨% សេវាកម្ម ១៦% មុខរបរមិនច្បាស់លាស់ (ចម្រុះ)៣.២០% ។

### 2. ស្ថានភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបង្កើតឡើងនៅឆ្នាំ១៩៩៤ រហូតដល់សព្វថ្ងៃមានការិយាល័យ ២០ ហើយចែកចេញជា ១០ការិយាល័យថ្នាក់ខេត្ត និង ១០ការិយាល័យថ្នាក់ស្រុក-ក្រុង ដោយមានមន្ត្រីសរុបចំនួន ៧៣នាក់ ក្នុងនោះមានស្រីចំនួន ២០នាក់ ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ដឹកនាំដោយប្រធានមន្ទីរ ១រូប អនុប្រធានមន្ទីរ ០៨រូប និងប្រធាន-អនុប្រធានការិយាល័យមន្ទីរ និងថ្នាក់ស្រុកចំនួន ៦៤នាក់ ។

## II. សកម្មភាពតាមការិយាល័យនីមួយៗថ្នាក់ខេត្ត

### 1. ការងាររដ្ឋបាល និងបុគ្គលិក

បច្ចុប្បន្នមន្ទីរមានបុគ្គលិកក្របខ័ណ្ឌសរុបចំនួន ៧៣នាក់ / ស្ត្រី ២០នាក់ គ្រប់គ្រងដោយប្រធានមន្ទីរ ០១រូប ទទួលបន្ទុកក្តាប់រួម និងអនុប្រធានមន្ទីរចំនួន ០៨រូប ក្នុងនោះមានស្ត្រី ០១រូប ។

- ការិយាល័យទាំង ១០ មានបុគ្គលិកសរុប ៤៤នាក់ / ស្ត្រីមាន ១២នាក់ ។
- ការិយាល័យអភិវឌ្ឍន៍ជនបទក្រុង និងស្រុកមានបុគ្គលិកសរុបចំនួន ២៩នាក់ / ស្ត្រីចំនួន ០៩នាក់ ។
- ធ្វើលិខិតចេញបានចំនួន ៦២ច្បាប់ និងទទួលលិខិតចូលចំនួន ៧៩ច្បាប់ ។
- បានរៀបចំបញ្ជីវត្តមានប្រចាំថ្ងៃ ចំពោះមន្ត្រីការិយាល័យថ្នាក់ខេត្ត ។
- ធ្វើរបាយការណ៍ប្រចាំខែកុម្ភៈ ជូនសាលាខេត្ត និងក្រសួងទៀងទាត់រៀងរាល់ប្រចាំខែ ។

### 2. ការងារគណនេយ្យ និងហិរញ្ញវត្ថុ (មិនទាន់មានសកម្មភាព)

| ជំពូក | បរិយាយ | ស្ថានភាពឥណទានគិត (៛) | បណ្តាខែមុន | ចំណាយក្នុងខែ | ចំណាយបូកយោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ទិញ | 180,800,000 | | | | 180,800,000 |
| ៦១ | សេវាខាងក្រៅ | 708,700,000 | | | | 708,700,000 |
| ៦៤ | បន្ទុកបុគ្គលិក | 686,200,000 | | 96,965,320 | 96,965,320 | 589,234,680 |
| **សរុប** | | **1,575,700,000** | **0** | **96,965,320** | **96,965,320** | |
| | | | | | | |

3. ការងារផែនការ និងស្ថិតិ

- រៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៥-២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ជាមួយការិយាល័យហិរញ្ញវត្ថុ ។
- ចូលរួមកសាងផែនការអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ ឆ្នាំ ២០១៥-២០១៩ និងកម្មវិធីវិនិយោគ ០៣ឆ្នាំ រំកិល ២០១៥-២០១៧ របស់រដ្ឋបាលសាលាខេត្តកំពង់ចាម ។
- រៀបចំប្រជុំពិភាក្សា និងការងារធ្វើបច្ចុប្បន្នភាពសៀវភៅផែនការត្រៀមបង្ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយឆ្នាំ ២០១៥ ។

**អធិការកិច្ច**

- ថ្ងៃទី ២៤-២៥ ខែធ្នូ ឆ្នាំ២០១៤ គណៈប្រតិភូអធិការកិច្ច ក្រសួងអធិការកិច្ច និងហិរញ្ញវត្ថុដឹកនាំដោយ ឯកឧត្តម វី រដេដ្ឋ ជាប្រធានគណៈប្រតិភូចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុ ការិយបរិច្ឆេទ ឆ្នាំ២០១៣-២០១៤ ការគ្រប់គ្រងចំណូល-ចំណាយ ថវិកាមូលធន ថវិកាវិនិយោគ និងថវិកាវិនិយោគបុរេប្រទាន ។

**កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:**

- ប្រធាន-អនុប្រធានមន្ទីរ និងមន្ត្រីរាជការមួយចំនួនបានចូលរួមប្រជុំផ្សេងៗចំនួន ៣៩លើក ។

## III. សកម្មភាពតាមវិស័យ

1. ការិយាល័យផ្លូវលំជនបទ

**១–** ការងារសាងសង់ផ្លូវអនុវត្តដោយគម្រោង RIP

- សាងសង់ផ្លូវដីក្រាលកំទេចថ្មភ្នំប្រវែង ១.៨៣២គ.ម និងមានស្ពាន ០១កន្លែង ប្រវែង ២០ម៉ែត្រ ស្ថិតនៅឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៤៥% ។
- ផ្សារភ្ជាប់ ០១កន្លែង ស្ថិតនៅឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៣៥% ។
- សាងសង់ផ្លូវក្រាលគ្រួសក្រហមប្រវែង ៣.៩៣៩គ.ម ស្ថិតនៅឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៤៥% ។

**២–** ការងារសាងសង់ផ្លូវរបស់គម្រោង ADB

- ចុះសិក្សាផ្លូវបេតុងប្រវែង ១១.៥៥០គ.ម របស់គម្រោង RRIP ស្ថិតនៅឃុំកោះសំរោង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។
- ចុះសិក្សាផ្លូវបេតុងប្រវែង ១៤.៧៨០គ.ម របស់គម្រោង RRIP ស្ថិតនៅឃុំកោះមិត្ត ស្រុកកំពង់សៀម ។
- ចុះសិក្សាផ្លូវបេតុងប្រវែង ១៨.៩២០គ.ម របស់គម្រោង RRIP ស្ថិតនៅឃុំកោះសូទិន ស្រុកកោះសូទិន ។

2. <u>ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ</u>

ការិយាល័យផ្គត់ផ្គង់ទឹកជនបទ ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ បានធ្វើផែនការដូចខាងក្រោម÷

**១– ការងារសាងសង់អណ្តូងអាហ្វ្រីដេស ចំនួន ១២អណ្តូង**

- ស្រុកចំការលើ ឃុំបុសខ្នុរ ភូមិសារ៉ាយ ចំនួន ០២អណ្តូង
  ភូមិបុសខ្នុរ ចំនួន ០១អណ្តូង
  ភូមិថ្កុកក្រវ៉ាន់ ចំនួន ០២អណ្តូង
- ស្រុកព្រៃឈរ ឃុំមៀន ភូមិឃ្លោយទី២ ចំនួន ០១អណ្តូង
  ឃុំជ្រៃវៀន ភូមិក្រឡោង ចំនួន ០២អណ្តូង
  ភូមិបន្ទាយរឹង ចំនួន ០២អណ្តូង
- ស្រុកកោះសូទិន ឃុំពង្រ ភូមិកំពង់ខ្ចុំច្រឹង ចំនួន ០១អណ្តូង
  ឃុំពាមប្រធ្នោះ ភូមិផ្សារថ្មី ចំនួន ០១អណ្តូង

**២– ការងារជួសជុលអណ្តូងស្នប់ចំនួន ៣៥អណ្តូង**

- ស្រុកបាធាយ ឃុំសណ្តែក ចំនួន ០៦អណ្តូង
  ឃុំទិនប់ ចំនួន ០២អណ្តូង
  ឃុំតាំងក្រសាំង ចំនួន ១០អណ្តូង
  ឃុំមេព្រីង ចំនួន ០៩អណ្តូង
  ឃុំត្រាប់ ចំនួន ០៨អណ្តូង

**៣– ការងារស្តារស្រះសហគមន៍ចំនួន ០១កន្លែង ទំហំ (៥០មx៣០មx៣ម)**

- ស្រុកស្ទឹងត្រង់ ឃុំទួលព្រះឃ្លាំង ភូមិវត្ត ចំនួន ០១ស្រះ

**៤– ការស្តាយប្រឡាយចំនួន ០១ខ្សែ ប្រវែង ១៥០០ម៉ែត្រ**

- ស្រុកកោះសូទិន ឃុំល្វេ ភូមិព្រែកសង្កែ ចំនួន ២០០ម៉ែត្រ
  ភូមិល្វេលើ ចំនួន } ១៥០០ម៉ែត្រ
  ភូមិទំពូង ចំនួន }

**៥– ការងារសាងសង់អាងត្រង់ទឹកភ្លៀងចំណុះ ៣៥ម៣ ចំនួន ០២អាង**

- ស្រុកចំការលើ ឃុំបុសខ្នុរ ភូមិដូនធី (សាលាបឋមសិក្សាដូនធី) ចំនួន ០១អាង
- ស្រុកព្រៃឈរ ឃុំត្រពាំងព្រះ ភូមិរលួស (សាលាបឋមសិក្សានរោត្តមរាមឫទ្ធ) ចំនួន ០១អាង

**៦– ការងារសហការជាមួយអង្គការ ១០០១**

- ចុះកំណត់ទីតាំងសាងសង់ស្ថានីយ៍ផលិតទឹកស្អាតបានចំនួន ១៤ស្ថានីយ៍ ក្នុងស្រុកចំនួន ០៤÷
  ១- ស្រុកកំពង់សៀម បានចំនួន ០៥ ស្ថានីយ៍
  ២- ស្រុកកងមាស បានចំនួន ០៣ ស្ថានីយ៍
  ៣- ស្រុកស្រីសន្ធរ បានចំនួន ០៣ ស្ថានីយ៍
  ៤- ស្រុកកោះសូទិន បានចំនួន ០១ ស្ថានីយ៍

3. <u>ការងារថែទាំសុខភាពជនបទ</u>

- ចុះបំផុសអនាម័យតាមសាលាដល់សិស្ស ចំនួន ១០សាលា ចំនួនគ្រូ ៤០នាក់/ស្រី ១៥នាក់ និងសិស្សចំនួន ៧៣៦នាក់/ស្រី ៣៨២នាក់ ស្មើនឹង ១០ឃុំ ស្មើ ៤ស្រុក ។
- ចុះពិនិត្យ និងវាយតម្លៃអនាម័យតាមសាលាចំនួន ១០សាលា ស្មើនឹង ១០ឃុំ មាន ៤ស្រុក មានគ្រូចូលរួមចំនួន ២០នាក់/ស្រី ០៩នាក់ ។ ការវាយតម្លៃជារួមឃើញថា តាមសាលាមានកំណើនអនាម័យល្អប្រសើរច្រើន ។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមប្រជុំការងារប្រចាំខែមករា ឆ្នាំ២០១៥ និងទិសទៅបន្ត ។
- ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលសន្និសិទចតុមុខ រាជធានីភ្នំពេញ ។
- ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលាខេត្តកំពង់ចាម ។

4. <u>ការងារអភិវឌ្ឍន៍សហគមន៍ជនបទ</u>

- ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមប្រជុំផ្សព្វផ្សាយស្តីពី តួនាទីភារៈកិច្ចថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យថ្នាក់ខេត្ត-ស្រុក មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។
- ថ្ងៃទី ១០-១៥ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះផ្សព្វផ្សាយពីអនាម័យនៅស្រុកព្រៃឈរ ។
- ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសន្និបាតបូកសរុបការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលសន្និសិទចតុមុខ ។
- ថ្ងៃទី ១៦-២០ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះតាមដាន និងពង្រឹងសម្ថភាព (គ.អ.ភ.) បានចំនួន ០៥ភូមិ ក្នុងឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ។
- ថ្ងៃទី ២៣-២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះតាមដាន និងពង្រឹងសម្ថភាព (គ.អ.ភ.) បានចំនួន ០៥ភូមិ ក្នុងឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសិក្ខាសាលាបញ្ចប់កម្មវិធីផ្នែកសុខភាពអាហាររូបត្ថម្ភ បំណិនជីវិត និងអនាម័យ ក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ហិរញ្ញបទានបន្ថែម នៅសាលាខេត្តកំពង់ធំ ។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមពិធីផ្សព្វផ្សាយលទ្ធផលសន្និបាតបូកសរុបការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលាខេត្តកំពង់ចាម ។

5. <u>ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>

**១- គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ**

- ស្រុកចំនួន ០៤ស្រុក ឃុំចំនួន ១៤ឃុំ ភូមិចំនួន ៤៣ភូមិ
- អតិថិជនសរុបចំនួន ៥១៥នាក់ ស្រីចំនួន ៦៧៨នាក់
- ក្រុមចំនួន ៤៧១ក្រុម
- ប្រាក់ដើមឱ្យខ្ចីចំនួន ១៨៩,៧០០,០០០ រៀល
- ប្រាក់ដើមសងចំនួន ១៦៧,៤៩៦,៥០០ រៀល
- ប្រាក់ការសងចំនួន ២៨,៧៥៣,២០០ រៀល
- ប្រាក់ដើមនៅជំពាក់ចំនួន ១,៣៩៧,៧៣៧,៦០០ រៀល

**២- គម្រោងឥណទានកូវ៉េ**

- ស្រុកចំនួន ០១ស្រុក ឃុំចំនួន ០១ឃុំ ភូមិចំនួន ០៤ភូមិ
- អតិថិជនសរុបចំនួន ២៣១នាក់ ស្រីចំនួន ១៨០នាក់
- ក្រុមចំនួន ៧៧ក្រុម
- ប្រាក់ដើមឱ្យខ្ចីចំនួន ២៨,៦០០,០០០ រៀល
- ប្រាក់ដើមសងចំនួន ២៣,៣១២,៣០០ រៀល
- ប្រាក់ការសងចំនួន ៤,៣៨២,៧០០ រៀល
- ប្រាក់ដើមនៅជំពាក់ចំនួន ២០៥,៧២៥,១០០ រៀល

6. <u>ការងារអភិវឌ្ឍន៍បណ្តុះបណ្តាល និងស្រាវជ្រាវ</u>

ដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីបង្កើនជំនាញជូនដល់ប្រជាពលរដ្ឋក្រីក្រ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានចាប់ផ្តើមបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវជំនាញមូលដ្ឋាន សំដៅឱ្យយុវជន យុវនារីក្រីក្រ កំព្រា ដែលមិនអាចមានលទ្ធភាពបន្តការសិក្សាទៅមុខទៀត ដើម្បីឱ្យពួកគេមានជំនាញមួយពិតប្រាកដ ។ ហើយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលដ្ឋាន បានធ្វើការផ្សព្វផ្សាយទៅដល់ភូមិ-ឃុំ តាមរយៈមន្ត្រីការិយាល័យស្រុក-ក្រុងទាំង ០៩ស្រុក ០១ក្រុង ខេត្តកំពង់ចាម និងបានផ្សព្វផ្សាយតាមវិទ្យុខេត្ត ដើម្បីជ្រើសរើសសិស្សចូលរៀនតាមមុខជំនាញ ។

- <u>ការងារបណ្តុះបណ្តាលក្នុងមជ្ឈមណ្ឌល</u>

ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តកំពង់ចាមសម្រេចបានការងារដូចខាងក្រោម÷

**១- បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្ស តាមវិទ្យុខេត្តដើម្បីចូលរៀនជំនាញ**

- ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំពង្រ ឃុំមហាលាភ ស្រុកកោះសូទិន ។ ជួបជាមួយក្រុមប្រឹក្សាឃុំទំនប់ ក្រុមប្រឹក្សាឃុំត្រប់ និងលោកប្រធានក្រុមប្រឹក្សាឃុំមេព្រីង ស្រុកបាធាយ ។ ជួបជាមួយក្រុមប្រឹក្សាឃុំស្រម៉រ ស្រុកព្រៃឈរ ដើម្បីផ្សព្វផ្សាយ ជូនដំណឹង ស្តីពី ការជ្រើសរើសសិស្សអោយចូលរៀនក្នុងមជ្ឈមណ្ឌលដែលគ្រោង និងបើកវគ្គបណ្តុះបណ្តាល ក្នុងខែមីនា ឆ្នាំ២០១៥ ខាងមុខនេះ ។

**២- ការតាមដាន និងវាយតម្លៃ**

- បានចុះទៅផ្ទះសិស្សក្នុងវគ្គទី១ ឆ្នាំ២០១៤ ដើម្បីពិនិត្យមើលការប្រកបមុខរបររបស់ពួកគាត់ក្រោយពីការបណ្តុះបណ្តាលរួច ដែលមានដូចជា÷
- លោក ឌុត ម៉េងអ៊ាង នៅភូមិកំពង់រាប ឃុំកំពង់រាប ស្រុកកោះសូទិន គាត់ជាជនពិការស្ទិតជើង កាលពីមុនគាត់ជាជាងកង់ ហើយគាត់មករៀនជួសជុលម៉ូតូនៅមជ្ឈមណ្ឌល សព្វថ្ងៃគាត់មានសកម្មភាពមមាញឹកក្នុងមុខរបររបស់គាត់ ។
- លោក ញ៉ក់ សុភ័ក្រ នៅភូមិតាំងជ្រៃ ឃុំសណ្តែក ស្រុកបាធាយ គាត់បានបើកកន្លែងជួសជុលម៉ូតូខ្លួនឯងនៅនឹងផ្ទះរបស់គាត់តែម្តង ។
- អ្នកស្រី អ៊ិន ស៊ីធឿន នៅភូមិរោងដំរី ឃុំត្រប់ ស្រុកបាធាយ គាត់ក៏បានបើកកន្លែងហាងកែសម្ផស្ស និងអ៊ុតសក់នៅផ្ទះរបស់ខ្លួនឯងដែរ ។

- **មន្ត្រីរាជការដែលកំពុងសហការជាមួយអង្គការអន្តរជាតិ និងអង្គការជាតិ**
  - គម្រោងឥណទាន ក្រសួងអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម ១៥នាក់

- អង្គការ ADB ០៦នាក់
- អង្គការយូនីសេហ្វ (UNICEF) ០៥នាក់
- កម្មវិធី RIP ០៤នាក់

❖ ការងារសហការជាមួយអង្គការ NGOs

- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានសហការណ៍ជាមួយអង្គការដៃគូមួយចំនួនដែលទទួលបានការគាំទ្រពីមូលនិធិអនាម័យសកល (Global Sanitation Fund) មានដូចជា អង្គការ Plan, អង្គការទឹកភ្លៀង, អង្គការ SNV, អង្គការ NAS, អង្គការ CHED, អង្គការទឹកស្អាត ១០០១, អង្គការ Water SHED និងអង្គការ UNICEF អប់រំអនាម័យតាមសាលារៀន និងសហគមន៍មូលដ្ឋាន ។

❖ គម្រោងឧបត្ថម្ភស្បៀងបន្ទាន់

- សិក្ខាសាលាបញ្ចប់គម្រោងអង្គការភ្លែន និងអង្គការដៃគូ ស្តីពី ការប្រតិបត្តិកម្មវិធីបំណិនជីវិត និងអាហាររូបត្ថម្ភដល់មាតា និងទារកក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែម ។

❖ ការងារអង្គការយូនីសេហ្វ

- ជួសជុលអណ្តូងស្នប់ ផ្តិស្តារដោយគ្រោះមហន្តរាយដែលគាំទ្រពីអង្គការយូនីសេហ្វចំនួន ២៥អណ្តូង ក្នុងនោះផ្តិស្តារជួសជុលស្នប់អាហ្វ្រីដេស ១៥ លើកខឿនកម្ពស់ ២ម៉ែត្រ ចំនួន ៤ និងផ្តិស្តារស្នប់លេខ ៦ ចំនួន ១០អណ្តូង ក្នុងនោះស្រុកកោះសូទិន បានចំនួន ០៤អណ្តូង លើកខឿនខ្ពស់ចំនួន ០១អណ្តូង ស្រុកកំពង់សៀម បានចំនួន ១០អណ្តូង លើកខឿនខ្ពស់បានចំនួន ០១អណ្តូង ស្រុកកងមាសចំនួន ១១អណ្តូង លើកខឿនបាន ។
- ចំនួន ២អណ្តូង និងអណ្តូងស្នប់លេខ ៦ ចំនួន ៨ លើកខឿនបានចំនួន ០២អណ្តូង ។
- ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៥ មានកិច្ចប្រជុំប្រចាំត្រីមាសលើកទី ២ ជាមួយអ្នកពាក់ព័ន្ធគម្រោងក្រោមហិរញ្ញប្បទានរបស់អង្គការយូនីសេហ្វ នៅមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម ។
- ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៥ ។

❖ ការងារយេនឌ័រ

- ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៥ លោកប្រធានមន្ទីរ លោកស្រីអនុប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំលើកទី ៣៣ របស់គណៈកម្មាធិការសម្របសម្រួលគម្រោងសាកល្បង នៅមន្ទីរកិច្ចការនារី ខេត្តកំពង់ចាម ។
- ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៥ លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំលើកទី ៦ របស់គណៈកម្មាធិការសម្របសម្រួលរួម (JCC) នៅសណ្ឋាគារភ្នំពេញ ។
- ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៥ លោក អ៊ឹង ចាន់ណារ៉េត អនុប្រធានចូលរួមកិច្ចប្រជុំប្រចាំខែមករា របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត នៅសាលាខេត្តកំពង់ចាម ។

7. <u>ការិយាល័យជនជាតិដើមភាគតិច</u> (គ្មានសកម្មភាព)

## IV. <u>**ទិសដៅផែនការឆ្នាំ ២០១៥**</u>

មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម បានខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាតិ អង្គការ សហគមន៍នានាឱ្យមានភាពកាន់តែប្រសើរឡើងដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋមានលក្ខណៈសមស្របពីមួយថ្ងៃទៅមួយថ្ងៃ និងស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

V. **បញ្ហាប្រឈម**

ស្របតាមសមិទ្ធផលដែលទទួលបានពីអនុវត្តន៍ការងារក្នុងឆ្នាំកន្លងមក មន្ទីរបានកត់សម្គាល់ឃើញថា មានការប្រឈមមួយចំនួននៅពេលចុះអនុវត្តន៍ការងារដូចជា ÷

- ការពង្រឹងធនធានមនុស្សដល់មន្ត្រីមន្ទីរនូវមានកម្រិត ព្រោះការបណ្តុះបណ្តាលជំនាញបច្ចេកទេស នៅពុំទាន់បានសមស្របតាមផ្លូវការ ។
- ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត ក្នុងការថែទាំសមិទ្ធផលដែលបានផ្តល់ការយល់ដឹងរបស់ប្រជាពលរដ្ឋ លើការថែទាំសុខភាព និងអនាម័យ អប់រំផ្សព្វផ្សាយបានទូលំទូលាយ ការផ្លាស់ប្តូរទម្លាប់របស់សហគមន៍នៅមានភាពយឺតយ៉ាវ ។

VI. **សន្និដ្ឋាន**

យោងតាមរបាយការណ៍អនុវត្តន៍គោលនយោបាយយុទ្ធសាស្រ្ត និងផែនការអភិវឌ្ឍន៍បានបង្ហាញឱ្យឃើញថា ដើម្បីអនុវត្តន៍ផែនការអភិវឌ្ឍន៍ជនបទ បានសម្រេចលុះត្រាតែយើងបានអនុវត្តនូវសកម្មភាពដូចខាងក្រោម÷

- ធ្វើអោយមានសកម្មភាពឡើងវិញនូវគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ដែលត្រូវបានចំណាត់ថ្នាក់ជាអាទិភាពនៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជនបទ ។
- ការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា សំណង់ធារាសាស្រ្ត ផ្លូវជនបទ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។ ដោយអនុវត្តន៍គោលនយោបាយយុទ្ធសាស្រ្ត និងផែនការអភិវឌ្ឍន៍ជនបទ របស់មន្ទីរបានបង្ហាញឱ្យឃើញថា ខេត្តកំពង់ចាម ទទួលបានការអភិវឌ្ឍន៍ដូចជា ស្ពាន និងផ្លូវលំជនបទខ្វាត់ខ្វែងសម្រាប់ប្រជាពលរដ្ឋធ្វើចរាចរណ៍ក្នុងការដឹកនាំកសិផលដែលជាកត្តា ធ្វើអោយប្រជាពលរដ្ឋកាន់តែជិតរវាងជនបទ និងទីប្រជុំជន ។ ធ្វើឱ្យប្រជាជនមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ ជាពិសេសធ្វើអោយយល់ដឹងពីសុខភាព និងអនាម័យតាមរយៈការអប់រំផ្សព្វផ្សាយ និងប្រើប្រាស់បង្គន់អនាម័យ ។

សរុបសេចក្តីមក យើងឃើញថា ការអនុវត្តន៍គោលនយោបាយ និងផែនការអភិវឌ្ឍន៍ជនបទ បានចូលរួមអនុវត្តន៍ឱ្យបានជោគជ័យនូវយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ អាណត្តិទី៥ និងគោលនយោបាយ ស្តីពី ការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ធ្វើឱ្យប្រជាពលរដ្ឋមានលំក្ខខ័ណ្ឌល្អប្រសើរក្នុងជីវភាពរស់នៅ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។

**ប្រធានមន្ទីរ**